# វិន័យទូទៅអំពីការចាប់ត្រីនៅតាមតំបន់ Nelson

- កុំចាប់ត្រីនៅក្រោមទំហំឲ្យសោះ។
- កុំចាប់យកច្រើនជាងកំណត់ចាប់ប្រចាំថ្ងៃឲ្យសោះ។
- មានតែជនដែលចាប់ ឬប្រមូលត្រីប៉ុណ្ណោះដែលអាចទាមទារយកកំណត់ចាប់ប្រចាំថ្ងៃបាន។
- លោកអ្នកមិនអាចប្រើគ្រឿងប្រដាប់ដកដង្ហើមនៅក្នុងទឹក (SCUBA) ឡើយពេលណាចាប់ ឬកាន់កាប់ខ្យងសមុទ្រ ឬប៉ាវហឺ (paua)។
- ត្រូវប្រើឧបករណ៍បន្ទះសំប៉ែតដោយប្រុងប្រយ័ត្ន ពេលណាគាស់យកខ្យងសមុទ្រ ឬប៉ាវហឺ។
- សូមវាស់ការចាប់របស់លោកអ្នកទាំងអស់ មុននឹងដាក់វាចូលទៅក្នុងថង់ចាប់របស់លោកអ្នក។
- ត្រីទាំងអស់ដែលនៅក្រោមទំហំ ហើយជាចំនួនលើស (មានរួមទាំងខ្យងសមុទ្រ ឬប៉ាវហឺ) ផងដែរនោះត្រូវដាក់វាចូលទៅក្នុងសមុទ្រវិញ ទោះថាវានៅរស់ ងាប់ ឬមានរបួសក្តី។
- កុំយកត្រីដែលនៅក្រោមទំហំ ហើយជាចំនួនលើសធ្វើជានុយឲ្យសោះ។
- ត្រូវរក្សាខ្យងសមុទ្រ ឬប៉ាវហឺ នៅក្នុងសំបករបស់វា រហូតទាល់តែលោកអ្នកចាកចេញពីមាត់សមុទ្រ។
- ហាមមិនឲ្យលក់ ឬជួញដូរការចាប់របស់លោកអ្នកឡើយ។
- លោកអ្នកអាចទិញត្រីបានតែពីហាង ឬហាងលក់ទំនិញធំៗប៉ុណ្ណោះ។

| របៀបវាស់ទំហំខ្យងសមុទ្រ ឬប៉ាវហឺ | របៀបវាស់ទំហំត្រី |
|---|---|
| **ខ្យងសមុទ្រ ឬប៉ាវហឺ:** វាស់ប្រវែងសំបកដែលធំជាងគេជាខ្សែបន្ទាត់ត្រង់។ កុំវាស់ពីលើសំបកកោងរបស់វា។ | **ត្រីមានព្រុយ:** ចាប់វាស់ពីច្រមុះត្រី ទៅពាក់កណ្តាលព្រុយកន្ទុយរបស់វា។ |
|  |  |

ត្រូវប្រើឧបករណ៍បន្ទះសំប៉ែត មិនមែនកាំបិត ឬទួរណឺវីសទេ ដើម្បីគាស់យកខ្យងសមុទ្រ ឬប៉ាវហឺ







| សត្វសមុទ្រ | | ចំនួនកំណត់ប្រចាំថ្ងៃ សំរាប់មនុស្សម្នាក់ | ទំហំតូចបំផុត (មម) |
|---|---|---|---|
|  | ប៉ាវហឺធម្មតា (ជើងខ្មៅ) | 10 | 125 |
|  | ប៉ាវហឺ ជើងលឿង | 10 | 80 |
|  | គ្រុំចំពុះទា | 50 | មិនកំណត់ទំហំទេ |
|  | ងាវ | 150 | មិនកំណត់ទំហំទេ |
|  | **Pipi** (ភីពភី) | 150 | មិនកំណត់ទំហំទេ |
| ថង់ដាក់ ត្រីសមុទ្ររួមគ្នា | ក្ដាម **cat's eyes, periwinkles,** ខ្យងទាក ខ្យងក្ដក់ ខ្យងសមុទ្រ **starfish** និងបង្កងទឹកសាប | 50 (ចំនួនរួមគ្នា) | មិនកំណត់ទំហំទេ |


ក្ដាម


ខ្យង Cat's-eye


ខ្យង Periwinkle


ខ្យងក្ដក់


ខ្យងទាក

| ត្រីមានព្រុយ | | ចំនួនកំណត់ប្រចាំថ្ងៃ សំរាប់មនុស្សម្នាក់ | ទំហំតូចបំផុត (មម) |
|---|---|---|---|
|  | ត្រី **Snapper – Nelson** | 10 | 250 |
| | ត្រី **Snapper – Marlborough Sounds** | 3 | 250 |
|  | ត្រី **Kahawai** | 20 | មិនកំណត់ទំហំទេ |
|  | ត្រី **Spotty** | មិនកំណត់ទេ | មិនកំណត់ទំហំទេ |
|  | ត្រី **Yellow eyed mullet** | មិនកំណត់ទេ | មិនកំណត់ទំហំទេ |

នេះគឺជាការណែនាំប៉ុណ្ណោះ។ ដើម្បីទទួលយកពត៌មានពិស្តារបន្ថែមទៀតអំពីបទបញ្ញាចាប់ត្រីរបស់យើង សូមទាក់ទង ជាមួយការិយាល័យរបស់ក្រសួងជលផល តាមទូរស័ព្ទលេខ **03 548 1069**

**www.fish.govt.nz**

២៤ មិថុនា ២០១០